Delete and use school letterhead

Delete and type date

Delete and type parent/carer name and address

## ការដាក់កន្លែងរៀនសម្រាប់ថ្នាក់ YEAR 7 ឆ្នាំក្រោយ

### PLACEMENT IN YEAR 7 NEXT YEAR

ឈ្មោះសិស្ស: Delete and type name of student

ឆ្នាំប្រក្រតិទិនសម្រាប់កន្លែងចូលរៀនថ្នាក់ Year 7: Delete and type calendar year for placement in Year 7

កាលបរិច្ឆេទដែលត្រូវបញ្ជូន *ពាក្យសុំចុះឈ្មោះដើម្បីចូលរៀន:* Delete and type date for return of Application to enrol

លេខទូរស័ព្ទសាលារៀន ប្រសិនបើលោកអ្នកត្រូវការជំនួយ: Delete and type school telephone number

ជូនចំពោះមាតាបិតា / អ្នកមើលថែ

សូមអរគុណលោកអ្នកចំពោះការបញ្ចេញនូវការចាប់អារម្មណ៍ សម្រាប់ទីកន្លែងចូលរៀនរបស់កូនលោកអ្នកមានឈ្មោះខាងលើនេះនៅថ្នាក់ Year 7 នៅសាលារៀននេះ។

ស្របទៅតាមការបញ្ចេញនូវការចាប់អារម្មណ៍របស់លោកអ្នក យើងបានសំគាល់ទុកកូនរបស់លោកអ្នកសម្រាប់គោលបំណងទីកន្លែងចូលរៀននៅក្នុងបញ្ជីចុះឈ្មោះរបស់យើងឆ្នាំក្រោយ។ លោកអ្នកប្រហែលជាបានជ្រាបហើយថា រហូតទាល់តែសាលារៀនបានយល់ព្រមទទួលពាក្យសុំចុះឈ្មោះដែលបានបំពេញសព្វគ្រប់ ដូច្នេះការចុះឈ្មោះរបស់កូនលោកអ្នកមិនទាន់បានបញ្ចប់នៅឡើយ។

ប្រសិនបើលោកអ្នកប្រាថ្នាបន្តការដាក់ពាក្យសុំចុះឈ្មោះនេះ សូមបំពេញជា**ភាសាអង់គ្លេស**នូវ *ពាក្យសុំចុះឈ្មោះចូលរៀននៅក្នុងសាលារៀនរដ្ឋ NSW (Application to enrol in a NSW government school)* ដែលភ្ជាប់មកជាមួយនេះ ហើយបញ្ជូនពាក្យសុំនេះមកឲ្យខ្ញុំវិញឲ្យបានទាន់កាលបរិច្ឆេទដូចចុះខាងលើនេះ។

លោកអ្នកនឹងកត់សម្គាល់ថា ពាក្យសុំនេះមានផ្នែកជាច្រើនដែលបានបំពេញរួចស្រេចសម្រាប់លោកអ្នក។ នេះគឺជាព័ត៌មានបច្ចុប្បន្នដែលយើងមាននៅក្នុងប្រព័ន្ធខុមព្យូធើរបស់យើង អំពីកូនរបស់លោកអ្នក។

1. សូមឆែកមើលគ្រប់ព័ត៌មានដែលបានបោះពុម្ព ហើយកែតម្រូវព័ត៌មានណាមួយ ប្រសិនបើត្រូវការ។
2. សូមបំពេញព័ត៌មានណាមួយដែលបាត់។
3. សូមឲ្យបានច្បាស់ប្រាកដថាលោកអ្នកឆ្លើយគ្រប់សំណួរចាំបាច់ទាំងអស់ ហើយចុះហត្ថលេខាលើពាក្យសុំ។

សូមកត់ចំណាំ:

- នេះគឺជាការចាំបាច់ដែលលោកអ្នកត្រូវឆ្លើយនូវគ្រប់ទាំងសំណួរនៅក្នុងពាក្យសុំ លើកលែងតែអំពីការងារ និងការអប់រំរបស់លោកអ្នក។
- ប្រសិនបើយើងមិនបានទទួលពាក្យសុំដើម្បីចុះឈ្មោះចូលរៀនរបស់លោកអ្នកទាន់កាលបរិច្ឆេទដូចចុះខាងលើនេះទេ យើងនឹងសន្មត់ថាលោកអ្នកឈប់មានការចាប់អារម្មណ៍ទៀតហើយ ហើយសិស្សផ្សេងទៀតនឹងត្រូវបានអញ្ជើញឲ្យដាក់ពាក្យសុំ។
- ប្រសិនបើលោកអ្នកដាក់ពាក្យសុំនេះ ក៏ប៉ុន្តែក្រោយមកបានផ្លាស់ប្តូរគំនិតរបស់លោកអ្នក ឬប្រសិនបើកាលៈទេសៈរបស់លោកអ្នកផ្លាស់ប្តូរ ហើយលោកអ្នកឈប់ប្រាថ្នាបន្តការចុះឈ្មោះ សូមទាក់ទងមកសាលារៀនឲ្យបានភ្លាម ដែលអាចធ្វើទៅបាន ដើម្បីឲ្យយើងអាចទាក់ទងជាមួយសិស្សផ្សេងទៀតដែលមានឈ្មោះនៅក្នុងបញ្ជីរង់ចាំរបស់យើង។

ពាក្យសុំរបស់លោកអ្នកនឹងត្រូវបានពិនិត្យមើលឡើងវិញ ហើយចាត់ចែងក្នុងអាទិភាពខ្ពស់បំផុត។ ប្រសិនបើពាក្យសុំរបស់លោកអ្នកត្រូវបានទទួលយក លិខិតបញ្ជាក់ជាផ្លូវការអំពីការចុះឈ្មោះមួយនឹងបានផ្ញើជូនលោកអ្នក។ នៅក្នុងកាលៈទេសៈខ្លះ យើងប្រហែលជាត្រូវតាមដានបន្តជាមួយលោកអ្នក លើចំណុចសំខាន់ខ្លះៗនៃព័ត៌មានដែលលោកអ្នកបានផ្តល់នៅក្នុងពាក្យសុំរបស់លោកអ្នក។ ប្រសិនបើការនេះកើតមានឡើង យើងនឹងទាក់ទងមកលោកអ្នក។

ប្រសិនបើលោកអ្នកត្រូវការជំនួយដើម្បីបំពេញពាក្យសុំ *Application to enrol in a NSW government school* សូមទាក់ទងមកសាលាបឋមសិក្សាក្នុងតំបន់របស់លោកអ្នក ឬទូរស័ព្ទមកយើងដើម្បីធ្វើការណាត់ពេលនិយាយជាមួយបុគ្គលិកសាលាមធ្យមសិក្សារបស់យើង។ ប្រសិនបើលោកអ្នកមានសំណួរណាមួយ សូមទាក់ទងមកសាលារៀន។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសាដើម្បីជួយលោកអ្នក លោកអ្នកអាចទូរស័ព្ទទៅសេវាបកប្រែភាសាតាមទូរស័ព្ទ លេខ 131 450 រួចស្នើសុំអ្នកបកប្រែមួយរូបដែលចេះនិយាយភាសារបស់លោកអ្នក។ អ្នកបកប្រែភាសានោះនឹងទូរស័ព្ទទៅសាលារៀន ហើយនៅរង់ចាំតាមទូរស័ព្ទដើម្បីជួយលោកអ្នកនៅក្នុងការសន្ទនា។ លោកអ្នកនឹងមិនត្រូវគេគិតថ្លៃចំពោះសេវានេះទេ។

សូមអរគុណចំពោះការជួយជ្រោមជ្រែងរបស់លោកអ្នក។

ដោយនូវសេចក្តីគោរពអំពីខ្ញុំ

នាយកសាលា
Principal